**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ចាម**
លេខៈ ០១១/២៤.... សណន

ថ្ងៃព្រហស្បតិ៍៩រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
កំពង់ចាម ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០២៤

# សេចក្តីណែនាំ
## ស្តីពី
## ការរៀបចំកិច្ចដំណើរការសិក្ខាសាលាសមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិល២០២៥-២០២៧ របស់រដ្ឋបាលខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់

**យោង** ៖- ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- អនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ
- លិខិតជម្រាបរបស់ក្រសួងមហាផ្ទៃ លេខ ២៩៧៨ សជណ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ ២០២៤ ស្តីពីការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ២០២៥-២០២៩ របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ប្រតិទិនការងារលេខ ១៤៨៨/២៣ លស ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០២៣ សម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៥-២០២៧) របស់រដ្ឋបាលខេត្ត
- ប្រតិទិនការងារលេខ ១៤២៧/២៤ លស ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០២៤ សម្រាប់កសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៥-២០២៩) របស់រដ្ឋបាលខេត្ត

ដើម្បីអនុវត្តន៍តាមគោលការណ៍ណែនាំស្តីពី ការរៀបចំកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ ២០២៥-២០២៩ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២៥-២០២៧ របស់រដ្ឋបាលខេត្ត ត្រូវផ្អែកតាមយុទ្ធសាស្ត្រ បញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បី **កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព**។ ទន្ទឹមនេះ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ បានកំណត់យកអាទិភាពគន្លឹះ ៥ គឺ **មនុស្ស ផ្លូវ ទឹក ភ្លើង** និង**បច្ចេកវិទ្យា** ។

ឈរលើមូលដ្ឋាននេះ រដ្ឋបាលខេត្តកំពង់ចាម សូមធ្វើការណែនាំដល់ លោក លោកស្រីប្រធាន មន្ទីរ អង្គភាពជុំវិញខេត្ត លោកអភិបាលនៃគណៈអភិបាលក្រុង ស្រុក លោក លោកស្រីមេឃុំ ចៅសង្កាត់ ស្តីពីការរៀបចំសិក្ខាសាលាសមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ សម្រាប់ឆ្នាំ២០២៤ ដែលនឹងចាប់ដំណើរការចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៤ នៅសាលាក្រុង ស្រុក ទូទាំងខេត្តកំពង់ចាមដូចខាងក្រោម៖

**១- មន្ទីរផែនការខេត្ត និងទីចាត់ការផែនការ និងវិនិយោគសាលាខេត្ត** ដែលជាសេនាធិការឱ្យក្រុមការងារកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលខេត្ត

មានតួនាទីជាអ្នកផ្តល់ការគាំទ្របច្ចេកទេស លើការរៀបចំកិច្ចដំណើរការសិក្ខាសាលាសមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២៥-២០២៧ របស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ឆ្នាំ២០២៤ និងជាអ្នកសម្របសម្រួល ក្នុងកិច្ចប្រជុំ និងផ្សព្វផ្សាយអំពីប្រតិទិនការងារ នីតិវិធីការរៀបចំសិក្ខាសាលានេះ ជូនស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តន៍ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

**២-មន្ទីរ-អង្គភាពជុំវិញខេត្ត** ត្រូវចាត់តាំងតំណាងរបស់ខ្លួនដែលមានសិទ្ធិសម្រេច និងចុះកិច្ចព្រមព្រៀងបណ្តោះអាសន្ន ចំពោះគម្រោងណាដែលខ្លួនបានគាំទ្រជាមួយរដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ក្នុងសិក្ខាសាលាសមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ឆ្នាំ២០២៤ តាមកាលបរិច្ឆេទដែលបានកំណត់ ។

**៣- អភិបាល នៃគណៈអភិបាលក្រុង ស្រុក និងជាប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុង ស្រុក** ត្រូវរៀបចំទីតាំងសិក្ខាសាលាសមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ ដែលមានប្រធានការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ ជាសេនាធិការឱ្យ ក្រុមការងារកសាងផែនការរបស់រដ្ឋបាលក្រុង ស្រុក ត្រូវអញ្ជើញអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនចូលរួម ទៅតាមកាលវិភាគរបស់គណៈអភិបាលខេត្ត ដែលបានភ្ជាប់ ។

**៤- មេឃុំ ចៅសង្កាត់** ត្រូវដឹកនាំ និងត្រៀមការងារមួយចំនួន ដើម្បីចូលរួមសិក្ខាសាលានេះ រួមមាន៖ រៀបចំគម្រោងអាទិភាពឃុំ សង្កាត់ ក្នុងឆ្នាំ២០២៤ សម្រាប់អនុវត្តឆ្នាំ២០២៥ ជាក្រដាសផ្ទាំងធំ តារាងលទ្ធផលនៃការអនុវត្តគម្រោងក្នុងឆ្នាំ២០២៤ជាក្រដាសផ្ទាំងធំ របាយការណ៍សង្ខេប ផែនទីឃុំ សង្កាត់ ដើម្បីចូលរួមក្នុងសិក្ខាសាលានេះ។

អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត សង្ឃឹមយ៉ាងមុតមាំថា ក្រោយពីទទួលបានសេចក្តីណែនាំនេះ លោក លោកស្រី ជាប្រធានមន្ទីរ អង្គភាពជុំវិញខេត្ត អភិបាល នៃគណៈអភិបាលក្រុង ស្រុក មេឃុំ ចៅសង្កាត់ ចូលរួមសហការអនុវត្តន៍ទៅតាមភារកិច្ចរៀងៗខ្លួន និងទទួលយកគម្រោងអាទិភាពក្នុងវិស័យនីមួយៗ សម្រាប់ការអនុវត្តន៍ឆ្នាំ២០២៥ ស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា ឱ្យទទួលបានជោគជ័យ ។

**អភិបាល នៃគណៈអភិបាលខេត្តកំពង់ចាម និងជា**
**ប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត**

អ៊ុន ចាន់ដា

**<u>ចម្លងជូន</u>**
-ក្រសួងមហាផ្ទៃ
-ក្រសួងផែនការ
(ដើម្បីគោរពជូនជ្រាប)
-គ្រប់អង្គការ សមាគមន៍មិនមែនរដ្ឋាភិបាលប្រចាំខេត្ត
-វិស័យឯកជន
(ដើម្បីសហការ)
-ឯកសារកាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកំពង់ចាម

## កាលវិភាគ គណៈអភិបាលខេត្ត អញ្ជើញជាអធិបតីក្នុងដំណើរការសិក្ខាសាលាសមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២៥-២០២៧របស់រដ្ឋបាល ក្រុង ស្រុក និងឃុំ សង្កាត់

ថ្ងៃចន្ទ ៤រោច ខែអស្សុជ ដល់ថ្ងៃសុក្រ ៨រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស២៥៦៨ ត្រូវនឹងថ្ងៃទី២១ ខែតុលា ដល់ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៤

| ល.រ | ក្រុង ស្រុក | ទីតាំង | គណៈអភិបាល | កាលបរិច្ឆេទ | | អ្នកទទួលសម្របសម្រួល | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | | ម៉ោង | ថ្ងៃ ខែ ឆ្នាំ | | |
| 1 | **បាធាយ** | សាលាស្រុក | ឯកឧត្តម **គន់ សុភា** | ០៧៖៣០ - ១១៖៣០ | ថ្ងៃចន្ទ ទី២១/១០/២០២៤ | មន្ទីរផែនការខេត្ត និងទីចាត់ការផែនការ និងវិនិយោគ | |
| 2 | **ចំការលើ** | សាលាស្រុក | ឯកឧត្តម **ខ្លូត ចិន្តា** | ០៧៖៣០ - ១១៖៣០ | ថ្ងៃចន្ទ ទី២១/១០/២០២៤ | មន្ទីរផែនការខេត្ត និងទីចាត់ការផែនការ និងវិនិយោគ | |
| 3 | **ជើងព្រៃ** | សាលាស្រុក | ឯកឧត្តម **ហាន កុសល** | ០៧៖៣០ - ១១៖៣០ | ថ្ងៃអង្គារ ទី២២/១០/២០២៤ | មន្ទីរផែនការខេត្ត និងទីចាត់ការផែនការ និងវិនិយោគ | |
| 4 | **កំពង់ចាម** | សាលាក្រុង | លោកជំទាវ **ប៉ាង ដានី** | ០៧៖៣០ - ១១៖៣០ | ថ្ងៃអង្គារ ទី២២/១០/២០២៤ | មន្ទីរផែនការខេត្ត និងទីចាត់ការផែនការ និងវិនិយោគ | |
| 5 | **កំពង់សៀម** | សាលាស្រុក | ឯកឧត្តម **ផេន សុផល** | ០៧៖៣០ - ១១៖៣០ | ថ្ងៃពុធ ទី២៣/១០/២០២៤ | មន្ទីរផែនការខេត្ត និងទីចាត់ការផែនការ និងវិនិយោគ | |
| 6 | **កងមាស** | សាលាស្រុក | ឯកឧត្តម **លី សារ៉ាវិទ្ធ** | ០៧៖៣០ - ១១៖៣០ | ថ្ងៃពុធ ទី២៣/១០/២០២៤ | មន្ទីរផែនការខេត្ត និងទីចាត់ការផែនការ និងវិនិយោគ | |
| 7 | **កោះសូទិន** | សាលាស្រុក | ឯកឧត្តម **សា ស៊ីថា** | ០៧៖៣០ - ១១៖៣០ | ថ្ងៃព្រ.ហ ទី២៤/១០/២០២៤ | មន្ទីរផែនការខេត្ត និងទីចាត់ការផែនការ និងវិនិយោគ | |
| 8 | **ព្រៃឈរ** | សាលាស្រុក | ឯកឧត្តម **ឡោ ចាន់លី** | ០៧៖៣០ - ១១៖៣០ | ថ្ងៃព្រ.ហ ទី២៤/១០/២០២៤ | មន្ទីរផែនការខេត្ត និងទីចាត់ការផែនការ និងវិនិយោគ | |
| 9 | **ស្រីសន្ធរ** | សាលាស្រុក | ឯកឧត្តម **ហេង វណ្ណានី** | ០៧៖៣០ - ១១៖៣០ | ថ្ងៃសុក្រ ទី២៥/១០/២០២៤ | មន្ទីរផែនការខេត្ត និងទីចាត់ការផែនការ និងវិនិយោគ | |
| 10 | **ស្ទឹងត្រង់** | សាលាស្រុក | ឯកឧត្តម **ស្រី សុវត្រ** | ០៧៖៣០ - ១១៖៣០ | ថ្ងៃសុក្រ ទី២៥/១០/២០២៤ | មន្ទីរផែនការខេត្ត និងទីចាត់ការផែនការ និងវិនិយោគ | |

ថ្ងៃព្រហស្បតិ៍ ៨រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស២៥៦៨

កំពង់ចាម ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០២៤

**អភិបាល នៃគណៈអភិបាលខេត្តកំពង់ចាម និងជា**

**ប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត**

**អ៊ុន ចាន់ដា**